# ថវិការបន្ថែម ដែលបានតាមរយ:ការស្នើសុំ នឹងអាចផ្តល់ជំនួយផ្ទាល់ដល់សាលា និងដើម្បីរក្សាបាននូវស្ថិរតាព។

| ការពិពណ៌នា | ថវិការចំណាយ | ប្រាក់ឧបត្ថម្ភ ដែលមាន |
|---|---|---|
| *ថវិការទាំងនេះនឹងបូកបន្ថែមលើថវិការរបស់សាលា ដោយហេតុនេះ អាចឲ្យ នាយក និង ក្រុមអ្នកដឹកនាំ របស់សាលា ប្រើប្រាស់ថវិការទាំងនេះ ឲ្យត្រូវទៅតាមសេចក្តីត្រូវការរបស់សិស្សានុសិស្ស។ ការចំណាយដែលត្រឹមត្រូវ រួមមាន៖* | | |
| • ប្រាក់បន្ថែមសម្រាប់សិស្សានុសិស្សដែលត្រូវការជំនួយបន្ថែម ដើម្បីប្រឡង Keystone ឲ្យជាប់។<br>• ការធ្វើអន្តរាគមន៍ក្នុងការរៀនអាន សម្រាប់សិស្សានុសិស្សដែលចេះអានទាបជាងពីរថ្នាក់ ឬ ទាបជាងនេះ នៃកម្រិតថ្នាក់។<br>• ការបម្រើសិស្សានុសិស្សផ្នែក សង្គមកិច្ច ផ្តល់ឱវាទ និង អាកប្បកិរិយា។<br>• សម្ភារៈដើម្បីជួយដល់ការបង្ហាត់បង្រៀន (ឧ. សម្ភារៈសិក្សា សៀវភៅមេរៀន សម្ភារៈសិល្បៈ និង បច្ចេកវិទ្យា ដើម្បីជួយដល់ការវាយតម្លៃ) និង សម្ភារៈសម្រាប់គ្រូ។ | ~១៥.០០០.០០០$ | តុលា/វិច្ឆិកា ២០១៤ |
| *ប្រាក់បន្ថែមតាមកន្លែង នឹងបែងចែកក្នុងចំណោមសាលាដែលមានសេចក្តីត្រូវការប្រហាក់ប្រហែលគ្នា រួមមាន៖* | | |
| • ការបង្រៀនបន្ថែមសម្រាប់សិស្សានុសិស្សដែលត្រូវការជំនួយបន្ថែមដើម្បីបញ្ចប់ការសិក្សា។<br>• ជំនួយក្នុងការបង្រៀនបន្ថែម សម្រាប់សកម្មភាពដែលអាចពន្លឿនគោលការណ៍ ទី១ និង ទី២។<br>• ជួយឲ្យរៀនលឿន សម្រាប់សិស្សានុសិស្សដែលចេះអានទាបជាងពីរថ្នាក់ ឬ ទាបជាងនេះ នៃកម្រិតថ្នាក់។<br>• កម្មវិធីអប់រំបន្ថែមតាមវិធីផ្សេងទៀតដែលមានគុណភាពខ្ពស់ និង បង្កើនសន្តិសុខនៅសាលាដែលគេបានចាត់ទុកថាជាសាលាដែលត្រូវការ ការធ្វើអន្តរាគមន៍ ឬ ការតាមដាន។ | ~១៥.០០០.០០០$ | មករា/កុម្ភៈ ២០១៥ |
| *ការគាំទ្រសិស្ស និង ប្រាក់ជំនួយ បន្ថែម ដើម្បីរក្សានូវស្ថិរតាព គេនឹងផ្តល់៖* | | |
| • ការបង្រៀនបន្ថែមសម្រាប់សិស្សានុសិស្សដែលត្រូវការជំនួយបន្ថែមដើម្បីបញ្ចប់ការសិក្សា (ឧ. កម្មវិធីរៀនគម្រប់ពិន្ទុ)។<br>• ការចំណាយដើម្បីរក្សាស្ថិរភាពឲ្យបាន នៅសាលា | ~១៣.៨០០.០០០$ | មេសា ២០១៥ |
| **សរុប** | **៤៣.៨០០.០០០$** | |